ISSN 1560-7615 / ISBN 978-99950-52-06-5

ទស្សនាវដ្ដី អភិវឌ្ឍន៍កម្ពុជា

ឯកសារបោះពុម្ពផ្សាយរបស់
វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ឆ្នាំទី ២០ លេខ ៤ ខែធ្នូ ២០១៦ តម្លៃ ១.៥០០៛

# ការប្រឈមចំពោះមុខរបស់អាជ្ញាធរមូលដ្ឋាន៖ ការកៀរគរធនធាន ការផ្តួចផ្តើមគំនិតនៅតាមមូលដ្ឋាន និងការចូលរួមរបស់ពលរដ្ឋ

## សេចក្ដីផ្ដើម

អត្ថបទនេះ មានគោលដៅជួយបំផុសការពិភាក្សាទៅលើ បញ្ហាថ្មីៗដែលអាជ្ញាធរមូលដ្ឋាននៅកម្ពុជា កំពុងប្រឈមមុខ និងខិតខំដោះស្រាយជាបន្តបន្ទាប់ ដើម្បីបំពេញតាមភារកិច្ចជាផ្លូវការ និងការរំពឹងនានា ដោយប្រឹងសម្របខ្លួនតាមតួនាទីនៅក្នុងបរិយាកាសកំពុងផ្លាស់ប្ដូរយ៉ាងលឿន តាំងពីពេល កំណែទម្រង់វិមជ្ឈការចាប់ផ្ដើមនៅឆ្នាំ ២០០២ មក។ ចំណុចលេចធ្លោជាងគេ គឺការបន្សុីគ្នារវាងការរំពឹងទុកដូចមានចែងនៅក្នុងតួនាទីជាមួយនឹងសមត្ថភាពនយោបាយ និងលទ្ធភាពអនុវត្តជាក់ស្ដែង។ ការលំបាកទាំងនេះកំពុងកើនឡើង ដោយសារកំណែទម្រង់តម្រូវឲ្យថ្នាក់មូលដ្ឋានមានចម្លើយតប និងការទទួលខុសត្រូវខ្ពស់ដោយផ្ទាល់ចំពោះប្រជាពលរដ្ឋ នៅពេលដែលពួកគេមិនទាន់ទទួលបានសិទ្ធិអំណាច ធនធាន និងជំនួយគាំទ្រគ្រប់គ្រាន់។

អត្ថបទនេះចាប់ផ្ដើមរៀបរាប់ពី ទំនាក់ទំនងដ៏មានសន្ទុះរវាងតួនាទីកំពុងវិវត្តទៅមុខរបស់អាជ្ញាធរមូលដ្ឋាន នឹងការរំពឹងកាន់តែខ្លាំងរបស់សាធារណជន និង ពីបែបបទដែលទំនាក់ទំនងទាំងពីរមុខនេះគួបគ្នាធ្វើឲ្យរីកគម្លាតរវាង គណនេយ្យភាព នឹងសមត្ថភាពរបស់ថ្នាក់មូលដ្ឋាន។ បន្ទាប់មកអត្ថបទមានវែកញែកយ៉ាងខ្លីថា ការភ្ជិតគម្លាតជាលក្ខខណ្ឌសំខាន់បំផុត ដើម្បីឲ្យអភិបាលកិច្ចនៅតាមមូលដ្ឋានមានគណនេយ្យភាព និងចម្លើយតប។ តមកទៀតមានការបំផុសឲ្យឃើញ និងពិភាក្សាអំពីបែបបទដែលតួអង្គថ្នាក់មូលដ្ឋានកំពុងព្យាយាមភ្ជិតគម្លាត និងដោះស្រាយបញ្ហាប្រឈមនានា។ នៅចុងបញ្ចប់ មានការផ្ដល់មតិផ្នែកគោលនយោបាយមួយចំនួន។



*អាជ្ញាធរថ្នាក់មូលដ្ឋានមកពីខេត្តជុំវិញបឹងទន្លេសាប ធ្វើទស្សនកិច្ចសិក្សាតាមខេត្តជាប់សមុទ្រ ដើម្បីធ្វើផែនការបន្សាំនឹងការប្រែប្រួលអាកាសធាតុនៅមូលដ្ឋានរបស់ខ្លួន។ ខេត្តកោះកុង ខែកុម្ភៈ ឆ្នាំ២០១៦*

## បរិយាកាសកំពុងផ្លាស់ប្ដូរក្នុងមូលដ្ឋាន៖ ការរំពឹង និងសមត្ថភាពរបស់អាជ្ញាធរមូលដ្ឋាន

កំណែទម្រង់វិមជ្ឈការ ដែលអ្នកគាំទ្រនានាមើលឃើញថាអាចជួយជំរុញរបបប្រជាធិបតេយ្យ ការអភិវឌ្ឍក្នុងមូលដ្ឋាន និងកាត់បន្ថយភាពក្រីក្រនោះ ជាក់ស្ដែងបាននាំឲ្យមានការផ្លាស់ប្ដូរគួរឲ្យកត់សំគាល់ ក្នុងរចនាសម្ព័ន្ធអភិបាលកិច្ចថ្នាក់ក្រោមជាតិនៅកម្ពុជា (Rusten et al. 2004)។ តាំងពីការបោះឆ្នោតឃុំ

## មាតិកា

ការប្រឈមចំពោះមុខរបស់អាជ្ញាធរមូលដ្ឋាន........................១
ការប្រៀបធៀបរបៀបអនុវត្តរបស់ សហគមន៍ព្រៃឈើមិនមែនជាប្រជាជនដើម នឹង សហគមន៍ព្រៃឈើជាប្រជាជនដើម ក្នុងការប្រើប្រាស់អុស និងអនុផលព្រៃឈើ.......................៦
តាមដានសេដ្ឋកិច្ច – ស្ថានភាពក្រៅប្រទេស ......................១៤
– ស្ថានភាពក្នុងប្រទេស.......................១៦
ព័ត៌មានថ្មីៗពីវិទ្យាស្ថាន CDRI .........................................២៤

---

អត្ថបទនេះ រៀបចំដោយ អេង នេត្រា ជាប្រធាន និងអ្នកស្រាវជ្រាវ ផ្នែកអភិបាលកិច្ច នៃវិទ្យាស្ថាន CDRI។ សូមយោងឯកសារនេះថា: Eng Netra. 2016. “Emerging Challenges of Cambodia’s Local Government: Resource Mobilisation, Local Initiative and Civic Engagement.” Cambodia Development Review 20(4): 1-5 ។ ភ្នំពេញ វិទ្យាស្ថាន CDRI។

សង្កាត់លើកទី១ ក្នុងឆ្នាំ២០០២ មក ថ្នាក់ឃុំបានដើរតួនាទីកាន់តែសំខាន់ក្នុងការអភិវឌ្ឍនៅតាមមូលដ្ឋាន។ នេះជាការផ្លាស់ប្តូរយ៉ាងច្បាស់មួយខុសពី អំឡុងពេលរបបខ្មែរក្រហមទើបដួលរលំ ដែលផ្តោតជាចម្បងទៅលើបញ្ហាសន្តិសុខ និងសណ្តាប់ធ្នាប់សង្គម។ កំណែទម្រង់វិមជ្ឈការ ក៏បានបង្កើតជាគ្រឹះមួយសម្រាប់ឲ្យក្រុមប្រឹក្សាឃុំសង្កាត់កសាងភាពពេញច្បាប់របស់ខ្លួន និងបង្កើតជាកន្លែងមួយ សម្រាប់ឲ្យអ្នកតំណាងមកពីគណបក្សផ្សេងៗចូលធ្វើការជាមួយគ្នា (Öjendal and Kim 2013)។ ខាងផ្នែករដ្ឋបាល កំណែទម្រង់វិមជ្ឈការបានដាក់អនុវត្តនូវ ក្របខ័ណ្ឌមួយសម្រាប់ឲ្យឃុំបានចូលរួមក្នុងដំណើរការអភិវឌ្ឍន៍ ដូចជាការកំណត់អាទិភាពគម្រោង ការគ្រប់គ្រងលទ្ធកម្មនិងហិរញ្ញវត្ថុជាដើម ដែលញ៉ាំងឲ្យក្រុមប្រឹក្សាឃុំ អាចឆ្លើយតបនឹងតម្រូវការក្នុងឃុំ និងលើកស្ទួយគណនេយ្យភាពក្នុងការសម្រេចចិត្តនៅថ្នាក់មូលដ្ឋាន។

ទោះបីមានការរីកចម្រើនដូចខាងលើក្តី ថ្នាក់ឃុំនៅទទួលបានមុខងារ និងធនធានតិចតួចណាស់ ដូច្នេះគួរមានការពង្រីកវិមជ្ឈការនៅថ្នាក់កណ្តាល (ខេត្ត និងស្រុក) ថែមទៀត (RGC 2005; Pak 2011)។ រដ្ឋាភិបាល ដោយមានជំនួយគាំទ្រពីដៃគូអភិវឌ្ឍន៍អន្តរជាតិនានា បានពង្រីកកំណែទម្រង់វិមជ្ឈការទៅថ្នាក់ស្រុក និងខេត្ត ដោយមានការបោះឆ្នោតជ្រើសតាំងដោយប្រយោលលើកទី១ នូវក្រុមប្រឹក្សាស្រុក និងខេត្ត ក្នុងឆ្នាំ២០០៩ និងថ្មីៗនេះទៀតក្នុងឆ្នាំ២០១៤។ ក្រុមប្រឹក្សាជ្រើសតាំងឡើងតាមការបោះឆ្នោតដោយប្រយោល ដែលមានសមាជិកមកពីគណបក្សនយោបាយខុសៗគ្នា និងមានទាំងស្ត្រីផងនោះ សព្វថ្ងៃបានចូលកាន់តំណែងពេញលេញ។ ស្ថាប័ន និងរចនាសម្ព័ន្ធថ្មីៗ ដូចជា គណៈអភិបាល និងការិយាល័យស្រុកផ្សេងៗត្រូវបានបង្កើតឡើងដើម្បីអនុវត្តតាមគោលនយោបាយ និងសេចក្តីសម្រេចនានារបស់ក្រុមប្រឹក្សា។ សមាសភាពគណៈអភិបាល រួមមាន អភិបាលមួយនាក់ អភិបាលរងច្រើននាក់ ហើយមានម្នាក់គត់ជាស្ត្រី។ ថ្នាក់ស្រុក ក៏មានថវិការបស់ខ្លួនផ្ទាល់ដែរ ដែលស្រុកអាចយកទៅប្រើសម្រាប់អនុវត្តផែនការអភិវឌ្ឍន៍ដោយមានការចូលរួមនៅថ្នាក់ស្រុក ដើម្បីឆ្លើយតបនឹងតម្រូវការក្នុងមូលដ្ឋាន។

ថ្នាក់ស្រុកឥឡូវនេះជា ចំណុចផ្តោតនៃកំណែទម្រង់វិមជ្ឈការដែលកំពុងបន្តទៅមុខ ដូចមានចែងក្នុងកម្មវិធីជាតិ ១០ឆ្នាំ ស្តីពីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិឆ្នាំ២០១០-២០១៩។ រដ្ឋាភិបាលចង់កែប្រែថ្នាក់ស្រុកចេញពី ថ្នាក់សម្របសម្រួលរដ្ឋបាល ឲ្យទៅជា កម្រិតនៃរដ្ឋអំណាចមួយមានសិទ្ធិសម្រេចអារកាត់ អាចជួយជំរុញការអភិវឌ្ឍសេដ្ឋកិច្ចក្នុងមូលដ្ឋាន និងផ្តល់សេវាផ្សេងៗដែលក្រុមប្រឹក្សាឃុំមានទំហំតូចជាង និងមានដែនកំណត់ខាងរដ្ឋបាលនោះ មិនអាចផ្តល់ឲ្យបាន។ ការប្រែប្រួលនេះតម្រូវឲ្យ ក្រុមប្រឹក្សាឃុំលើកយកសំណើទទួលបានពីប្រជាជនខ្លួន ដើម្បីឲ្យស្រុកជួយដោះស្រាយ។ ស្រុកក៏មានភារកិច្ចជួយទ្រទ្រង់ដល់ឃុំឲ្យអនុវត្តការងារ ជួយឃ្លាំមើល និងផ្ទៀងផ្ទាត់ភាពស្របច្បាប់នៃសេចក្តីសម្រេចនានារបស់ឃុំ ព្រមទាំងផ្តល់ការបណ្តុះបណ្តាលសមត្ថភាពដល់ក្រុមប្រឹក្សាឃុំផងដែរ។

ការស្រាវជ្រាវរបស់ CDRI ស្តីពីកំណែទម្រង់វិមជ្ឈការ និងអភិបាលកិច្ចនៅតាមមូលដ្ឋាន បានរកឃើញការផ្លាស់ប្តូរសំខាន់ៗ ៣។ ទី១ វិមជ្ឈការបានបើកផ្លូវឲ្យមានតួអង្គ និងសំឡេងថ្មីៗផុសឡើង ហើយតាមនេះ នយោបាយនៅថ្នាក់មូលដ្ឋានក៏មានលក្ខណៈពហុបក្សមួយកម្រិតដែរ។ ក្នុងឃុំ និងស្រុកភាគច្រើន គេឃើញមានសមាជិកក្រុមប្រឹក្សាមកពីគណបក្សធំទាស់ និងសមាជិកក្រុមប្រឹក្សាជាស្ត្រី។ សម្ពាធនៃការបោះឆ្នោតជ្រើសតាំងក្រុមប្រឹក្សាឃុំដោយផ្ទាល់ បានរីកធំហួតប៉ះពាល់ដល់ប្រព័ន្ធគណបក្សនយោបាយ ហើយគណបក្សនានាក៏ត្រូវកែប្រែសម្របខ្លួនឯងឡើងវិញ និងបង្កើនប្រសិទ្ធភាពនៅក្នុងស្រទាប់មហាជនដោយស្វែងរកបេក្ខជនមានសមត្ថភាពល្អដើម្បីឈ្នះឆ្នោត (Thon et al. 2009)។ ក្នុងរដ្ឋអំណាចថ្នាក់ស្រុក មន្ត្រីជាច្រើននាក់សុទ្ធតែជាមនុស្សជំនាន់ក្រោយសង្គ្រាម និងមានកម្រិតអប់រំល្អគួរសម បើធៀបនឹងមន្ត្រីចូលនិវត្តន៍ភាគច្រើន (Eng 2014)។

ទី២ ការរៀបចំរចនាសម្ព័ន្ធ និងគណនេយ្យភាពអាជ្ញាធរមូលដ្ឋាន (ឃុំ និងស្រុក) ឡើងវិញ កន្លងមកឃើញថា បានជួយលើកស្ទួយទំនាក់ទំនងរដ្ឋ-សង្គម គណនេយ្យភាព និងចម្លើយតបរបស់អាជ្ញាធរមូលដ្ឋានចំពោះប្រជាជនខ្លួន។ ការស្រាវជ្រាវស្តីពីទំនាក់ទំនងរដ្ឋ-សង្គម នៅកម្ពុជា បានរកឃើញការប្រែប្រួលក្នុងបែបបទដែលពលរដ្ឋចូលពាក់ព័ន្ធជាមួយអាជ្ញាធរ ពោលគឺ ការវិវត្តចេញពី ទំនាក់ទំនងប្រកបដោយការភ័យខ្លាច ទៅជា ទំនាក់ទំនងប្រកបដោយការគោរពរាប់អាន ទោះបីជា ឋានានុក្រម និងទំនាក់ទំនងផ្ទាល់ខ្លួននៅតែសំខាន់ក្តី (Öjendal and Kim 2006)។ ការសិក្សាមួយស្តីពី ទំនាក់ទំនងផ្ទាល់ខ្លួនរបស់ថ្នាក់ដឹកនាំក្នុងបីឃុំ ក៏បានរកឃើញដែរថា អ្នកភូមិនៅតាមជនបទតែងហៅ ថ្នាក់ដឹកនាំក្នុងមូលដ្ឋាន ដោយប្រើពាក្យសំគាល់ញាតិ ដូចជា អ៊ុំ ពូ មីង ឬ តា ដើម្បីបង្ហាញពីភាពជិតស្និទ្ធ និងការរាប់អាន ក៏ដូចជាកាតព្វកិច្ចរបស់ថ្នាក់ដឹកនាំនៅកម្រិតមូលដ្ឋាន ក្នុងការការពារ និងថែទាំអ្នកភូមិខ្លួន គឺដូចជាសមាជិកគ្រួសារត្រូវអនុវត្តជាមួយគ្នាដូច្នោះដែរ (Thon et al. 2009)។ ការសិក្សានោះបង្ហាញទៀតថា តួអង្គនៅកម្រិតមូលដ្ឋានតែងតែលំអៀងទៅខាងអ្នកភូមិខ្លួន លើកលែងតែនៅក្នុងទំនាស់ជាប់ទាក់ទងជាមួយនឹងតួអង្គមានអំណាចខ្លាំងមកពីក្រៅ។

ទី៣ កំណែទម្រង់វិមជ្ឈការបានផ្តល់ឱកាសថ្មីមួយសម្រាប់ឲ្យពលរដ្ឋ សង្គមស៊ីវិល និងម្ចាស់ជំនួយអន្តរជាតិ បានពាក់ព័ន្ធនិងធ្វើការជាមួយរដ្ឋអំណាច ដើម្បីញ៉ាំងឲ្យអាជ្ញាធរមូលដ្ឋានកាន់តែមានតម្លាភាព និងគណនេយ្យភាព និងដើម្បីជួយដល់ការអនុវត្តគម្រោងអភិវឌ្ឍន៍ក្នុងមូលដ្ឋាន។ អ្នកបោះឆ្នោតសព្វថ្ងៃបានយល់ដឹងកាន់តែច្បាស់ពីតម្លៃនៃសន្លឹកឆ្នោតរបស់ខ្លួន ហើយសកម្មជាងមុនក្នុងការជ្រើសរើសអ្នកដឹកនាំមានចិត្តល្អ និងបោះឆ្នោតទម្លាក់អ្នកដឹកនាំដែលធ្វើបាបខ្លួន បើសិនជាគាត់មានជម្រើស (Öjendal and Kim 2013)។ អង្គការសង្គមស៊ីវិល និងអង្គការមិនមែនរដ្ឋាភិបាល (NGO) ដែលដើរតួនាទីសំខាន់ក្នុងការអភិវឌ្ឍប្រទេសកម្ពុជា កន្លងមកអាចធ្វើការជាមួយអាជ្ញាធរមូលដ្ឋានក្នុងការបំផុសឲ្យឃើញពីតម្រូវការរបស់ពលរដ្ឋ ចូលរួមក្នុងការធ្វើផែនការនិងដំណើរការសម្រេចចិត្តក្នុងមូលដ្ឋាន ព្រមទាំងអនុវត្តគម្រោង

អភិវឌ្ឍន៍ផ្សេងៗ។ការអនុវត្តគំនិតផ្តួចផ្តើមកសាងគណនេយ្យភាពសង្គម អាចជួយពង្រីកថែមទៀតនូវ ឱកាសសម្រាប់ឲ្យពលរដ្ឋ និងតំណាងសង្គមស៊ីវិល មកចូលរួមជាមួយអាជ្ញាធរមូលដ្ឋាន ក្នុងការផ្តល់សេវាសាធារណៈមួយចំនួន។

ទោះបីកំណែទម្រង់វិមជ្ឈការនិងអភិបាលកិច្ចនៅតាមមូលដ្ឋានមានការជឿនលឿនដូច្នេះក្តី ក៏លទ្ធផលស្ថិតក្រោមការពិនិត្យតាមដានកាន់តែខ្លាំង ហើយអាចខូចខាត ព្រោះគម្លាតរវាងការរំពឹងរបស់សាធារណជន ជាមួយនឹងសមត្ថភាពឆ្លើយតបរបស់អាជ្ញាធរមូលដ្ឋាន កំពុងរីកធំឡើងយ៉ាងលឿន។ ការវិភាគប្រជាសាស្រ្តកម្ពុជាបង្ហាញថា មជ្ឈដ្ឋានអ្នកបោះឆ្នោតសព្វថ្ងៃ មានលក្ខណៈកាន់តែចម្រុះបែបឡើង ជាពិសេសក្នុងចំណោមប្រជាជនវ័យក្មេងអាយុក្រោម ៣០ឆ្នាំ។ ប្រជាជនវ័យក្មេងគឺ មិនសូវប៉ះពាល់ដោយប្រវត្តិសាស្រ្តគួរឲ្យតក់ស្លុតរបស់កម្ពុជានោះទេ មានការអប់រំល្អជាងអ្នកជំនាន់មុន មានលទ្ធភាពប្រសើរជាងក្នុងការទទួលបានព័ត៌មាន មានលក្ខណៈចល័តខ្លាំង និងធ្លាប់ជួបពាក់ព័ន្ធច្រើននឹងពិភពខាងក្រៅ។ ការរំពឹងថា អាជ្ញាធរមូលដ្ឋាន អាចឆ្លើយតបបានតាមតម្រូវការរបស់ប្រជាជនវ័យក្មេងទាំងនោះ គួបផ្សំនឹងការរំពឹងរបស់អាជ្ញាធរថ្នាក់លើៗ កន្លងមកបានដាក់សម្ពាធយ៉ាងខ្លាំងទៅលើអាជ្ញាធរមូលដ្ឋាន ហើយអាចធ្វើឲ្យខូចខាតដល់ភាពពេញសិទ្ធិ និងសារៈសំខាន់របស់ថ្នាក់មូលដ្ឋាននេះ។

ដំណើរការផ្តល់សមត្ថភាពឲ្យអាជ្ញាធរមូលដ្ឋាន ពោលគឺធនធាន សិទ្ធិអំណាច និងស្វ័យភាព ដើម្បីឆ្លើយតបនឹងការរំពឹងក្នុងមូលដ្ឋាន និងការទាមទារកាន់តែច្រើន វានៅយឺតយ៉ាវខ្លាំង។ នៅកម្រិតឃុំ ទោះបីអាជ្ញាធរមានភាពពេញសិទ្ធិខាងនយោបាយហើយក្តី ក៏ភារកិច្ច និងធនធាននៅមានតិចណាស់។ ថ្នាក់ស្រុក ដែលកំណែទម្រង់វិមជ្ឈការ កំពុងយកចិត្តទុកដាក់ក្នុងបញ្ហាផ្តល់សេវានេះ បច្ចុប្បន្នទោះបីនៅខ្វះមូលដ្ឋានអំណាចបែបប្រជាធិបតេយ្យក្តី ក៏មានសក្តានុពលច្រើនដែរ សម្រាប់ការអភិវឌ្ឍក្នុងមូលដ្ឋាន។ ប៉ុន្តែការផ្តល់ធនធាន និងសិទ្ធិអំណាចសម្រាប់មុខងារផ្តល់សេវារបស់ថ្នាក់ស្រុក ដូចមានចែងក្នុង ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្តក្រុង ស្រុកខណ្ឌ ឆ្នាំ២០០៨ (ច្បាប់រៀបចំអង្គការ) មិនទាន់បានអនុវត្តពេញលេញនៅឡើយទេ។ ការសិក្សាថ្មីៗមួយបង្ហាញថា ចម្លើយតបរបស់ស្រុកទៅនឹងសំណើរបស់ពលរដ្ឋ និងក្រុមប្រឹក្សាឃុំ នៅតែត្រូវរាំងស្ទះដោយសារ ចំណូលដ៏ខ្សត់ខ្សោយបានពីប្រភពរបស់ខ្លួនផ្ទាល់ និងការរារែកទាញយកមកប្រើនូវសិទ្ធិអំណាចសម្រេចអារកាត់ដែលច្បាប់បានអនុញ្ញាត (NCDD 2016)។

សមត្ថភាពមានកម្រិតរបស់អាជ្ញាធរមូលដ្ឋាន កាន់តែចោទខ្លាំងឡើង ដោយសារថ្នាក់នេះនៅជិតជាប់នឹងបញ្ហា ត្រូវធ្វើអន្តរកម្មភ្លាមៗជាមួយពលរដ្ឋ និងរងការស្តីបន្ទោសជាបន្ទាប់ពីសំណាក់មហាជនលើបញ្ហាផ្សេងៗដែលកើតមានឡើងនៅក្នុងមូលដ្ឋាន។ រដ្ឋាភិបាលថ្នាក់លើក៏កាន់តែរំពឹងថា អាជ្ញាធរមូលដ្ឋានអាចគ្រប់គ្រងទប់ទល់បញ្ហាក្នុងតំបន់របស់ខ្លួន កុំឲ្យវាធ្ងន់ធ្ងរ ឬរីករាលដាលថែមទៀត។ ការចូលរួមរបស់ បណ្តាអង្គការសង្គមស៊ីវិល និង NGOs ជាមួយអាជ្ញាធរមូលដ្ឋាន តាមរយៈ គំនិតផ្តួចផ្តើមធ្វើកំណែទម្រង់ផ្សេងៗ ក៏ដាក់សំពាធបន្ថែមដែរ ព្រោះវាបង្វែរការយកចិត្តទុកដាក់ចេញពីរដ្ឋាភិបាលថ្នាក់ជាតិ មកថ្នាក់មូលដ្ឋានលើលទ្ធផលនៃសកម្មភាពផ្តល់សេវា។ ការរំពឹង និងសម្ពាធទាំងនេះ បានធ្វើឲ្យអាជ្ញាធរមូលដ្ឋានស្ទះដំណើរការ។ ចំណុចខ្វះខាតដូចខាងលើ បានប៉ះពាល់ខ្លាំងដល់អាជ្ញាធរមូលដ្ឋាន ព្រោះសេចក្តីសម្រេចជាច្រើនស្តីពីការផ្ទេរសិទ្ធិអំណាច និងធនធាន ពីក្រសួងស្ថាប័ននានាទៅឲ្យថ្នាក់នេះ វានៅយឺតយ៉ាវណាស់ ទោះបីរដ្ឋាភិបាលថ្នាក់មជ្ឈឹមបានប្តេជ្ញាធ្វើកំណែទម្រង់វិមជ្ឈការ ឲ្យបានកាន់តែស៊ីជម្រៅក្តី។

## បញ្ហាប្រឈមផុសឡើងថ្មីសម្រាប់អាជ្ញាធរមូលដ្ឋាន

បញ្ហាប្រឈមធំៗបីបានផុសឡើង នៅពេលថ្នាក់មូលដ្ឋានព្យាយាមកាត់បន្ថយគម្លាតរវាង ការរំពឹងរបស់សាធារណជនជាមួយនឹងសមត្ថភាពផ្តល់ចម្លើយតប និងបង្ហាញគណនេយ្យភាពដល់ប្រជាជនក្នុងមូលដ្ឋាន គឺមាន ការផ្តួចផ្តើមគំនិតក្នុងមូលដ្ឋាន ការកៀងគរធនធាន និងការចូលរួមរបស់ពលរដ្ឋ។

### *បញ្ហាប្រឈមទី១៖ ការផ្តួចផ្តើមគំនិតក្នុងមូលដ្ឋាន*

គម្លាតកាន់តែធំរវាង ការរំពឹង នឹងសមត្ថភាពជាក់ស្តែង ធ្វើឲ្យស្ថាប័នរដ្ឋកាន់តែខ្វះលទ្ធភាព ត្រូវរារែក ឬខ្វះសិទ្ធិអំណាច ដោះស្រាយសំណើរបស់សាធារណជន ប្រកបដោយប្រសិទ្ធភាព។ នៅកម្រិតមូលដ្ឋាន បញ្ហាប្រឈមជារឿយៗ វាធំហួសព្រំដែនសមត្ថកិច្ចរបស់អាជ្ញាធរមូលដ្ឋាន។ ដោយឡែក បញ្ហាផ្នែកគោលនយោបាយចម្បងៗក្នុងមូលដ្ឋាន ដូចជាខាង ហេដ្ឋារចនាសម្ព័ន្ធ ការបង្កើតការងារ ការស្រោចស្រព ការប្រើប្រាស់ដី និងអភិបាលកិច្ចធនធានធម្មជាតិ អាចស្ថិតនៅក្នុងមុខងារសម្រេចអារកាត់របស់ថ្នាក់មូលដ្ឋាន ប៉ុន្តែមិនទាន់បានផ្ទេរឲ្យមកនៅក្រោមសមត្ថកិច្ចរបស់ថ្នាក់នេះនៅឡើយទេ។

ដើម្បីអាចមានចម្លើយតបចំពោះបញ្ហាចោទក្នុងមូលដ្ឋានដូចជាស្វែងរកជំនួយគាំទ្រ និងកិច្ចសហការពីសំណាក់ក្រសួងជំនាញនានា ឬពីប្រជាជនក្នុងស្រុកនោះ អាជ្ញាធរមូលដ្ឋានត្រូវអនុវត្តសិទ្ធិអំណាចរបស់ខ្លួន និងសម្រេចអារកាត់ដោយមានលក្ខណៈប្រជាធិបតេយ្យ។ មកទល់បច្ចុប្បន្ន ទោះបីមានការផ្តល់ឲ្យថ្នាក់មូលដ្ឋាននូវសិទ្ធិអំណាចច្រើនណាស់ហើយ ដូចមានចែងក្នុងច្បាប់ស្តីពីរដ្ឋបាល និងការគ្រប់គ្រងឃុំសង្កាត់ (ច្បាប់ឃុំសង្កាត់ឆ្នាំ២០០១) និង ច្បាប់រៀបចំអង្គការឆ្នាំ២០០៨ ក្តី ក៏ការសិក្សានានាបានបង្ហាញថា ថ្នាក់មូលដ្ឋាននៅរារែក និងជួបកំហិត ក្នុងការអនុវត្តសិទ្ធិអំណាច និងគំនិតផ្តួចផ្តើមផ្សេងៗ (NCDD 2012; Eng 2014)។ បញ្ហានេះមួយចំណែកមកពី ច្បាប់បានចែងតែត្រួសៗពី ភារកិច្ចជាទូទៅសម្រាប់អាជ្ញាធរមូលដ្ឋាន ដូច្នេះរដ្ឋាភិបាលថ្នាក់មជ្ឈឹមត្រូវមានចេញ សេចក្តីណែនាំលំអិត (ដែលបច្ចុប្បន្នមិនទាន់មានទេ) ដើម្បីបញ្ជាក់ពីបែបបទដែលអាជ្ញាធរមូលដ្ឋាន ត្រូវដាក់អនុវត្តសេចក្តីចែងទាំងនោះ។ បញ្ហាធំជាងនេះទៀតគឺវាអាចមានគ្រោះថ្នាក់ដល់បុគ្គលនិង/ឬផ្នែកនយោបាយ បើសិនថ្នាក់មូលដ្ឋាន ផ្តួចផ្តើមគំនិតដោយផ្ទាល់ ពោលគឺការភ័យខ្លាចមានប្រតិកម្មមិនល្អពីមជ្ឈដ្ឋានអ្នកបោះឆ្នោត ពីរដ្ឋាភិបាលថ្នាក់លើ និងពីតួអង្គខាងក្រៅដែលមានអំណាចខ្លាំង។

ការសិក្សានានាបង្ហាញថា ដើម្បីឲ្យអាជ្ញាធរមូលដ្ឋានមានគណនេយ្យភាព និងក្លាយជាអ្នកផ្ដល់សេវាមានចម្លើយតបល្អ កំណែទម្រង់វិមជ្ឈការត្រូវកែប្រែថ្នាក់នេះចេញពី ស្ថាប័នរដ្ឋបាលទទួលភារកិច្ចពីថ្នាក់មជ្ឈឹម (គឺគ្រាន់តែប្រតិបត្តិតាម និងឆ្លើយតបតាមគោលនយោបាយ និងបទបញ្ជាពីថ្នាក់មជ្ឈឹម) ឲ្យទៅជា អង្គភាពថ្នាក់មូលដ្ឋានហ៊ានផ្ដល់មតិប្រកបដោយទំនុកចិត្ត ទទួលបានសិទ្ធិអំណាចអនុវត្តភារកិច្ច ប្រកបដោយស្វ័យភាពកាន់តែច្រើន ហើយសំខាន់បំផុត អាចប្រើប្រាស់គំនិតផ្ដួចផ្ដើមរបស់ខ្លួនដោះស្រាយក្ដីបារម្ភផ្សេងៗនៅក្នុងមូលដ្ឋាន។ ដោយសារមានគម្លាតកាន់តែធំរវាង ការរំពឹងរបស់សាធារណជន នឹងសមត្ថភាពរបស់អាជ្ញាធរមូលដ្ឋាន នៅក្នុងបរិបទនៃការប្រើវិធីសាស្ត្រអនុវត្តវិមជ្ឈការឲ្យស៊ីជម្រៅជាបណ្ដើរៗនោះ ការផ្ដួចផ្ដើមគំនិត និងការបំផុសស្មារតីជាម្ចាស់ ក្នុងការសម្រេចចិត្តនៅថ្នាក់មូលដ្ឋាន គឺសំខាន់ខ្លាំងណាស់ ដើម្បីពង្រឹងអំណាចបែបប្រជាធិបតេយ្យរបស់អ្នកភូមិនៅតាមជនបទ ដែលថ្នាក់នេះត្រូវធ្វើជាអ្នកតំណាង។ វិទ្យាស្ថាន CDRI បានស្រាវជ្រាវឃើញថា លទ្ធផលការងាររបស់អាជ្ញាធរមូលដ្ឋាន ប្រែប្រួលខុសគ្នាទៅតាមបរិបទ ប៉ុន្តែពឹងផ្អែកខ្លាំងទៅលើគំនិតផ្ដួចផ្ដើមរបស់ថ្នាក់ដឹកនាំ។ ការផ្ដួចផ្ដើមគំនិត ត្រូវមានការដឹកនាំផង និងការលើកទឹកចិត្តយ៉ាងសកម្ម សហប្រតិបត្តិការ និងការគាំទ្រពីរដ្ឋអំណាចថ្នាក់លើៗផង។ ក្នុងពេលជាមួយគ្នា ថ្នាក់មូលដ្ឋានក៏ត្រូវមានកិច្ចការពារ ពីការស្ដីបន្ទោសជាផ្លូវការផ្សេងៗដល់ការសាកល្បងអនុវត្តគំនិតថ្មីៗ ឬវិធីសាស្ត្រថ្មី ដើម្បីឆ្លើយតបនឹងការរំពឹងរបស់សាធារណជនដែរ។

## ***បញ្ហាប្រឈមទី២៖ ការកៀងគរធនធាន***

កំណែទម្រង់វិមជ្ឈការផ្ដល់នូវតួនាទី និងភារកិច្ចច្រើនបែបយ៉ាងដល់អាជ្ញាធរមូលដ្ឋាន មានតាំងពី សេវារដ្ឋបាលស៊ីវិលនានា រហូតដល់ ការផ្ដល់សេវាមូលដ្ឋាន និងការដោះស្រាយទំនាស់។ ពីមួយឆ្នាំទៅមួយឆ្នាំ កំណើនធនធានហិរញ្ញវត្ថុជាបណ្ដើរៗ បានអនុញ្ញាតឲ្យអាជ្ញាធរមូលដ្ឋានបំពេញភារកិច្ចរបស់ខ្លួន និងផ្ដល់សេវាមួយចំនួន។ ការផ្ទេរមូលនិធិពីរដ្ឋាភិបាលថ្នាក់ជាតិ ទៅថ្នាក់មូលដ្ឋានសម្រាប់ធ្វើជាមូលនិធិឃុំសង្កាត់ បានកើនយ៉ាងទៀងទាត់ ពី ២% នៃចំណូលក្នុងស្រុកក្នុងឆ្នាំ២០០២ រហូតដល់ ២,៨% ក្នុងឆ្នាំ២០១៦។ ស្រដៀងគ្នាដែរ ប្រាក់ផ្ទេរពីចំណូលក្នុងស្រុក សម្រាប់មូលនិធិស្រុក/ខណ្ឌ បានកើនយឺតៗពី ០,៨%ក្នុងឆ្នាំ២០១៣ ដល់ ០,៩%ក្នុងឆ្នាំ២០១៦។ ប៉ុន្តែ ចំណាយរដ្ឋបាល និងប្រតិបត្តិការឃុំនិងស្រុក បានស្រូបយកមូលនិធិទាំងនេះអស់ច្រើន ហើយធនធានដែលឃុំនិងស្រុកមាន សម្រាប់ប្រើដើម្បីឆ្លើយតបនឹងតម្រូវការក្នុងមូលដ្ឋាន និងផ្ដល់សេវាផ្សេងៗដូចច្បាប់បានកំណត់ វានៅខ្វះខាតជាខ្លាំង។ ច្បាប់ឃុំឆ្នាំ២០០១ និង ច្បាប់រៀបចំអង្គការឆ្នាំ២០០៨ បានអនុញ្ញាតឲ្យរដ្ឋអំណាចមូលដ្ឋាននូវប្រភពមូលនិធិជាច្រើនទៀត មានដូចជា ចំណូលពន្ធ និងចំណូលមិនមែនពន្ធផ្សេងៗ ក្នុងនោះមានទាំង បទបញ្ញត្តិលើចំណូលពីប្រភពផ្ទាល់ខ្លួនផង ប៉ុន្តែបច្ចុប្បន្ននេះមិនទាន់បានអនុវត្តទេ។

នៅពេលនេះ កិច្ចប្រឹងប្រែងកៀងគរធនធានក្នុងស្រុកដើម្បីដោះស្រាយបញ្ហាក្នុងស្រុកដែលបានរកឃើញ វាកើតចេញពីឱកាសចាំបាច់ផ្សេងៗ ជាប់ទាក់ទងនឹងសកម្មភាពគម្រោងរបស់ម្ចាស់ជំនួយ និង NGO និងទំនាក់ទំនងផ្ទាល់ខ្លួនជាមួយអ្នកទទួលផលនៅកម្រិតមូលដ្ឋាន និងកម្រិតជាតិ។ របៀបរបបនេះ ចោទបញ្ហាច្រើន ដល់តួអង្គក្នុងស្រុកក្នុងការអនុវត្តភារកិច្ចខ្លួន និងពិបាកសម្រាប់ប្រជាពលរដ្ឋក្នុងការដាក់សម្ពាធឲ្យអាជ្ញាធរមូលដ្ឋានកាន់តែមានគណនេយ្យភាព។ សរុបមក អាជ្ញាធរមូលដ្ឋាននៅកម្ពុជាត្រូវមានកញ្ចប់ថវិកាកាន់តែធំ និងមានប្រភពចំណូលច្រើនបែបយ៉ាង ដែលជួយឲ្យមហាជនមើលឃើញថាថ្នាក់នេះមិនមែនគ្រាន់តែជា ស្ថាប័នមួយរបស់រដ្ឋាភិបាលថ្នាក់ជាតិនោះទេ ប៉ុន្តែគឺជា រដ្ឋអំណាចថ្នាក់មូលដ្ឋានពិតៗដែលមានគណនេយ្យភាព និងមានការឆ្លើយតបចំពោះប្រជាជននៅក្នុងមូលដ្ឋាន។

## ***បញ្ហាប្រឈមទី៣៖ ការចូលរួមរបស់ពលរដ្ឋ***

បញ្ហាប្រឈមទី៣ ទាក់ទងនឹងការចូលរួមរបស់សាធារណជននៅក្នុងអភិបាលកិច្ច នៅកម្រិតមូលដ្ឋាន គណនេយ្យភាព និងភាពចាំបាច់ត្រូវធ្វើការពាក់ព័ន្ធជាមួយប្រជាពលរដ្ឋដែលមាន ផលប្រយោជន៍ យេនឌ័រ អាយុ និងស្ថានភាពសេដ្ឋកិច្ចសង្គមកិច្ចខុសៗគ្នា។ ការចូលរួមពីសាធារណជន មិនត្រឹមតែសំខាន់បំផុតនៅក្នុងអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងញ៉ាំងឲ្យសេចក្ដីសម្រេច និងសកម្មភាពនានារបស់អាជ្ញាធរមូលដ្ឋាន អាចឆ្លើយតបតាមតម្រូវការ និងតំណាងឲ្យម្ចាស់ឆ្នោតរបស់ខ្លួនទៀតផង។ ការធ្វើការជាមួយប្រជាពលរដ្ឋ ផ្ដល់លទ្ធភាពឲ្យមន្ត្រីថ្នាក់មូលដ្ឋានអាចផ្ដល់សេវា ស្របតាមតម្រូវការដែលរកឃើញនៅក្នុងមូលដ្ឋាន។ ការចូលរួមយ៉ាងសកម្មពីសំណាក់សាធារណជន ក៏ចាំបាច់ដែរសម្រាប់កសាងទំនាក់ទំនងមានគណនេយ្យភាពកាន់តែរឹងប៉ឹងរវាង មន្ត្រីក្នុងមូលដ្ឋាន នឹងមជ្ឈដ្ឋានអ្នកបោះឆ្នោត។

អភិបាលកិច្ចនៅតាមមូលដ្ឋានកំពុងវិវត្តទៅមុខ គួបផ្សំនឹងការប្រែប្រួលផ្នែកប្រជាសាស្ត្រ គូសបញ្ជាក់ពីភាពចាំបាច់ និងបន្ទាន់ ត្រូវឲ្យប្រជាជនវ័យក្មេងជំនាន់ថ្មី និងកាន់តែសំខាន់នេះ ចូលពាក់ព័ន្ធក្នុងអភិបាលកិច្ចនៅតាមមូលដ្ឋាន។ ថ្វីបើកាន់តែលេចធ្លោឡើងក្ដី យុវជនដែលតំណាងឲ្យ ៦០% នៃប្រជាជនសរុប ជារឿយៗនៅតែដាច់ឆ្ងាយពីប្រព័ន្ធផ្លូវការ និងដំណើរការសម្រេចចិត្តក្នុងមូលដ្ឋាន។ ការស្រាវជ្រាវរបស់វិទ្យាស្ថាន CDRI ស្ដីពីការចូលរួមផ្នែកនយោបាយរបស់ យុវជនក្នុងការធ្វើផែនការអភិវឌ្ឍន៍ឃុំនៅតាមជនបទ បង្ហាញថា បណ្ដាស្ថាប័នថ្នាក់ឃុំមិនទាន់បានរៀបចំខ្លួន ដើម្បីទទួលយក និងធ្វើការពាក់ព័ន្ធជាមួយយុវជនឲ្យបានផុសផុលនៅឡើយទេ (Heng et al. 2014)។

បញ្ហាប្រឈមសម្រាប់អាជ្ញាធរមូលដ្ឋាននៅកម្ពុជានេះ គឺសំខាន់បំផុត ព្រោះអាជ្ញាធរមិនត្រឹមតែត្រូវដាក់បញ្ចូលយុវជន និងគោលគំនិតរបស់ក្រុមពលរដ្ឋថ្មីនេះទៅក្នុងដំណើរការអភិបាលកិច្ចក្នុងមូលដ្ឋាននោះទេ ប៉ុន្តែក្នុងពេលជាមួយគ្នាក៏ត្រូវសម្របខ្លួនតាម និងឆ្លើយតបនឹងតម្រូវការដោយឡែករបស់យុវជនដែរ។

## សេចក្ដីសន្និដ្ឋាន

អាជ្ញាធរមូលដ្ឋាននៅកម្ពុជា មានការផ្លាស់ប្ដូរច្រើនតាំងពីកំណែទម្រង់វិមជ្ឈការបានចាប់ផ្ដើមនៅឆ្នាំ២០០២ មក។ បរិបទសេដ្ឋកិច្ចសង្គមកិច្ចនិងនយោបាយដែលក្នុងនោះអាជ្ញាធរមូលដ្ឋានត្រូវរស់រាន និងដំណើរការ ក៏បានផ្លាស់ប្ដូរដូចគ្នាដែរ ជាពិសេសគឺមាន យុវជនជំនាន់ក្រោយបានផុសឡើងនៅប្រទេសកម្ពុជាក្នុងសម័យបច្ចុប្បន្ន ហើយកំពុងក្លាយយ៉ាងលឿនជាប្រជាជនក្រុមធំជាងគេ និងមានចិត្តគំនិតខុសប្លែកខ្លាំងពីមនុស្សជំនាន់ចាស់។ ទោះយ៉ាងនេះក្ដី ការពង្រឹងសមត្ថភាពស្ថាប័នសម្រាប់ការធ្វើកំណែទម្រង់ដោយអាជ្ញាធរមូលដ្ឋាន វានៅយឺតយ៉ាវជាង ការរំពឹងកាន់តែមានច្រើនបែបយ៉ាងរបស់សាធារណជន។ គម្លាតរីកធំរវាង ការរំពឹងលើសេវាសាធារណៈ នឹងសមត្ថភាពផ្ដល់សេវានេះ បានធ្វើឲ្យអាជ្ញាធរមូលដ្ឋានស្ថិតក្រោមសម្ពាធ និងការពិនិត្យតាមដានកាន់តែខ្លាំងឡើងពីសំណាក់មជ្ឈដ្ឋានអ្នកបោះឆ្នោត និងរដ្ឋអំណាចថ្នាក់លើៗ។ ក្នុងការព្យាយាមកាត់បន្ថយគម្លាតនេះ អាជ្ញាធរមូលដ្ឋានត្រូវជួបបញ្ហាប្រឈមចម្បងៗបី។

តួអង្គថ្នាក់មូលដ្ឋានមានគំនិត និងដំណោះស្រាយល្អៗ សម្រាប់ឆ្លើយតបនឹងបារម្ភក្នុងមូលដ្ឋាន ប៉ុន្តែជារឿយៗ តែងរារែកក្នុងការធ្វើសកម្មភាពស្របតាមគំនិតខ្លួន និងអនុវត្តជាក់ស្ដែងនូវសិទ្ធិអំណាចដែលច្បាប់សព្វថ្ងៃបានផ្ដល់ឲ្យ។ ការផ្ដួចផ្ដើមគំនិត និងភាពជាម្ចាស់លើការសម្រេចចិត្តផ្សេងៗ កន្លងមកតែងត្រូវរាំងស្ទះដោយសារកង្វះធនធាន និងសិទ្ធិអំណាចក្នុងការកៀងគរប្រមូលធនធាន។ ការប្រែប្រួលផ្នែកប្រជាសាស្ត្រ និងកំណើនសារៈសំខាន់នៃប្រជាជនវ័យក្មេង បានចោទជាបញ្ហាដល់អាជ្ញាធរមូលដ្ឋានក្នុងការស្វែងរកយុទ្ធសាស្ត្រថ្មីៗ ដើម្បីញាំងឲ្យមានការចូលរួមរបស់សាធារណជន និងការផ្ដល់សេវាក្នុងមូលដ្ឋាន។

បញ្ហាផ្សេងៗដែលអាជ្ញាធរមូលដ្ឋានត្រូវប្រឈមមុខ ទំនងកាន់តែតឹងតែងឡើងទៀតក្នុងអនាគតយ៉ាងខ្លី លើកលែងតែមានការយកចិត្តទុកដាក់ជាបន្ទាន់។ រដ្ឋាភិបាលបានតម្រង់ទិសកិច្ចប្រឹងប្រែងឡើងវិញ ទៅផ្ដោតលើស្ថានភាពនេះ ក្នុងការដាក់អនុវត្តផែនការទី៣ ដំណាក់កាលទី២ ដោយប្រឹងជំរុញការអនុវត្តមុខងារនានាដែលបានអនុញ្ញាតហើយ ពង្រីកការផ្ទេរមុខងារតាមវិស័យ និងអនុវត្តតាមក្របខ័ណ្ឌគណនេយ្យភាពសង្គម (NCDD 2014)។ ទោះយ៉ាងនេះក្ដី ត្រូវមានកិច្ចប្រឹងប្រែងធ្វើកំណែទម្រង់កាន់តែស្វាហាប់ និងស៊ីជម្រៅថែមទៀត ដើម្បីឲ្យអាជ្ញាធរមូលដ្ឋាន និងស្ថាប័នផ្សេងៗរបស់ថ្នាក់នេះ មានស្វ័យភាព ធនធាន និងគណនេយ្យភាពកាន់តែច្រើនហើយអាចដោះស្រាយបញ្ហាប្រឈមទាំងឡាយកាន់តែមានប្រសិទ្ធភាពខ្ពស់។

## ឯកសារយោង


Eng Netra. 2014. “The Politics of Decentralisation in Cambodia: The District Level.” PhD thesis, School of Politics and Social Inquiry, Monash University, Melbourne, Australia.

Heng Seiha, Vong Mun and Chheat Sreang with Chhuon Nareth. 2014. *The Enduring Gap: Decentralisation Reform and Youth Participation in Local Rural Governance*. Working Paper Series No. 94. Phnom Penh: CDRI.

NCDD (National Committee for Sub-National Democratic Development) 2012. Mid-term Review of Implementation Plan 2011-2013 of NP-SNDD. Phnom Penh: RGC.

NCDD 2014. Implementation Plan 3 Phase II of the NP-SNDD. Phnom Penh: NCDD.

Öjendal, Joakim, and Kim Sedara. 2006. “*Korob, Kaud, Klach*: In Search of Agency in Rural Cambodia.” *Journal of Southeast Asian Studies* 37(3): 507-526.

Öjendal, Joakim, and Kim Sedara. 2013. “Reconciliation in Cambodia? Decentralisation as a Post-Conflict Strategy.” In *The Imperative of Good Local Governance: Challenges for the Next Decade of Decentralisation*, edited by Joakim Öjendal and Anki Dellnäs. Tokyo: United Nations University Press.

Pak Kimchoean. 2011. *Fiscal Decentralisation in Cambodia: A Review of Progress and Challenges*. Working Paper Series No. 50. Phnom Penh: CDRI.

RGC (Royal Government of Cambodia). 2005. Strategic Framework for Decentralisation and Deconcentration. Phnom Penh: RGC.

Rusten, Caroline, Kim Sedara, Eng Netra and Pak Kimchoen. 2004. *The Challenges of Decentralisation Design in Cambodia*. Phnom Penh: CDRI.

Thon Vimealea, Ou Sivhuoch, Eng Netra and Ly Tem. 2009. *Leadership in Local Politics of Cambodia: A Study of Leaders in Three Communes of Three Provinces*. Working Paper Series No. 42. Phnom Penh: CDRI.